# មជ្ឈមណ្ឌលឯកសារកម្ពុជា

# គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

# (១៩៧៥–១៩៧៩)

## ការចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## វេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

## រវាងគ្រូ សិស្ស និងឪពុកម្តាយ

## លើកទី១

## ភូមិអន្លង់វែង ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០



*សិស្សចូលរួមក្នុងការធ្វើវេទិកាសាធារណៈស្តីពីការអប់រំ*

មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាផ្លូវការមួយ ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៤។ ជាផ្នែកមួយនៅក្នុងគម្រោងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ចំនួន៣០០.០០០ច្បាប់ ដើម្បីចែកដល់អនុវិទ្យាល័យ និងវិទ្យាល័យចំនួនជាង

១.៥០០កន្លែងក្នុងទូទាំងប្រទេសកម្ពុជា ។ បន្ថែមទៅលើការចែកចាយសៀវភៅប្រវត្តិសាស្ត្រនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានបើកវគ្គបណ្តុះបណ្តាលគ្រូឯកទេសប្រវត្តិវិទ្យា អក្សរសាស្ត្រខ្មែរ និងសីលធម៌-ពលរដ្ឋ ពីគរុកោសល្យនិងវិធីសាស្ត្រក្នុងការបង្រៀន ដើម្បីឲ្យគាត់មានជំនាញក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមសាលារៀន ។ រហូតមកដល់បច្ចុប្បន្ននេះ គ្រូឯកទេសប្រវត្តិវិទ្យាចំនួនជាង១.០០០នាក់មកពីខេត្តចំនួន១៨ បានទទួលការបណ្តុះបណ្តាលរួចហើយ ។ នៅបំណាច់ឆ្នាំ២០១១នេះ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជននិងកីឡា នឹងធ្វើការបើកវគ្គបណ្តុះបណ្តាលរបៀបដូចគ្នានេះដល់គ្រូចំនួនជាង៣.២០០នាក់បន្ថែមទៀត ។

ដូចមានជាភស្តុតាងស្រាប់នៅក្នុងវគ្គបណ្តុះបណ្តាលគ្រូ ដែលបានប្រារព្ធធ្វើឡើងនៅក្នុងខែធ្នូឆ្នាំ២០០៩ នាពេលកន្លងមក ចំណេះដឹងរបស់គាត់ស្តីអំពីរបបខ្មែរក្រហម គឺដឹងត្រឹមតែបទពិសោធន៍ផ្ទាល់ខ្លួន បទពិសោធន៍របស់សាច់ញាតិ និងមិត្តភក្ត្រប៉ុណ្ណោះ ។ នៅចុងបញ្ចប់វគ្គបណ្តុះបណ្តាល សិក្ខាកាមម្នាក់មកពីខេត្តកណ្តាលបានថ្លែងអំណរគុណដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងគ្រូឧទ្ទេសថ្នាក់ជាតិ ដែលបានបង្រៀនគាត់អំពីប្រវត្តិសាស្ត្រខ្លួនឯង ។ គាត់បាននិយាយថា *“វគ្គបណ្តុះបណ្តាលនេះ បានជួយខ្ញុំឲ្យមានការស្វែងយល់កាន់តែច្រើនថែមទៀត ។ ឧទាហរណ៍ ខ្ញុំបានដឹងត្រឹមតែមន្ទីរសន្តិសុខពីរបីប៉ុណ្ណោះ ។ ដោយសារតែឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានដឹងថាមានមន្ទីរសន្តិសុខចំនួនជិត២០០កន្លែង ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម”* ។ ការគិតនេះមិនត្រឹមតែកើតមានចំពោះសិក្ខាកាមមកពីខេត្តកណ្តាលប៉ុណ្ណោះទេ ប៉ុន្តែហាក់ដូចជាកើតមានឡើងចំពោះសិក្ខាកាមនានាដែលមកពីគ្រប់កន្លែងទាំងអស់ ។ ឧទាហរណ៍ សិក្ខាកាមស្ត្រីម្នាក់មកពីខេត្តបាត់ដំបងបានថ្លែងថា គាត់បានដឹងតិចតួចណាស់អំពីរបបខ្មែរក្រហម ប៉ុន្តែឥឡូវគាត់បាននិយាយថា *“ខ្ញុំដឹងច្រើនណាស់អំពីខ្មែរក្រហមនយោបាយ និងមនោគមន៍វិជ្ជារបស់ខ្មែរក្រហម ។ ខ្ញុំមានអាយុជាង២០ឆ្នាំហើយ គឺប្រហែលជា២៤ឆ្នាំ នៅពេលដែលខ្មែរក្រហមកាន់កាប់អំណាច ។ ឥឡូវនេះ ខ្ញុំអាចចែករំលែករឿងរ៉ាវជាមួយអ្នកទាំងអស់គ្នានៅវគ្គបណ្តុះបណ្តាលនេះបាន”* ។

ដោយសារតែការយល់ឃើញបែបនេះ ទើបមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានទទួលស្គាល់អារម្មណ៍បែបនេះកើតមាននៅក្នុងចំណោមប្រជាជនកម្ពុជាភាគច្រើន និងបានព្យាយាមក្នុងការបំពេញបន្ថែមនូវស្ថានភាពនេះ ។ ហេតុដូច្នេះហើយ ទើបមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រារព្ធធ្វើវេទិកាសាធារណៈស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅខែសីហា ឆ្នាំ២០១០ ដើម្បីលើកកម្ពស់ដល់ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម បង្កើនការផ្សះផ្សា និងការការពារឧក្រិដ្ឋកម្មអមនុស្សធម៌ដែលបានកើតមាននៅក្នុងប្រទេសកម្ពុជា ។ គោលបំណងនៃគម្រោងនេះមានដូចខាងក្រោម៖

១) ផ្តល់ការអប់រំក្រៅប្រព័ន្ធស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅដល់សហគមន៍ ដែលផ្តោតជាចម្បងទៅលើប្រជាជនដែលរស់នៅទីជនបទឆ្ងាយៗ និងមានលទ្ធភាពតិចតួចបំផុតក្នុងការទទួលបានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងឯកសារផ្សេងៗទៀតស្តីអំពីរបបខ្មែរក្រហម ។

២) ផ្តល់ឱកាសដល់អ្នកភូមិដែលជាជនរងគ្រោះនិងជនដៃដល់ ឲ្យបង្កើតការពិភាក្សានិងសហការជាមួយលោកគ្រូអ្នកគ្រូ ក្នុងការបង្រៀនដល់កូនចៅរបស់ខ្លួនអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ។

៣) វេទិកានេះ មិនត្រូវបានបង្កើតឡើងដើម្បីបង្រៀនដល់អ្នកភូមិឲ្យផ្តល់ការបង្រៀនដល់កូនៗរបស់គាត់ឡើយ ប៉ុន្តែដើម្បីពាំនាំនូវចំណេះដឹងពីបរិបទប្រវត្តិសាស្ត្រដ៏ធំធេងប្រាប់ដល់សហគមន៍ និងបង្កើតឲ្យមានការពិភាក្សាពីប្រវត្តិផ្ទាល់ខ្លួនម្នាក់ៗឆ្លងកាត់របបខ្មែរក្រហម ។

ដូចមានជាភស្តុតាងស្រាប់នៅក្នុងការចូលរួមផ្តល់យោបល់ និងសំណួររបស់អ្នកចូលរួមនៅក្នុងវេទិកាសាធារណៈនៅខេត្តកំពង់ស្ពឺនេះ អ្នកភូមិជាច្រើននាក់ក៏ដូចជាសិក្ខាកាមជាគ្រូប្រវត្តិសាស្ត្រដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាផ្លូវការពីអំពើប្រល័យពូជសាសន៍ មានការយល់ដឹងតិចតួចពីបរិបទនយោបាយសង្គម និងការបង្កប់អត្ថន័យរបស់ខ្មែរក្រហម ។ ឧទាហរណ៍ អ្នករស់រានពីរបបខ្មែរក្រហមម្នាក់អាចចងចាំពីបទពិសោធន៍គាត់ក្នុងរបបខ្មែរក្រហម ហើយរឿងរ៉ាវខ្លះត្រូវបានប្រាប់ទៅកាន់គាត់ ប៉ុន្តែមិនបានបញ្ជាក់ពីអត្ថន័យបង្កប់យ៉ាងទូលំទូលាយ ឬពីរចនាសម្ព័ន្ធច្បាប់របស់ខ្មែរក្រហមទេ ។ លើសពីនេះទៅទៀត អ្នកចូលរួមខ្លះបានសួរសំណួរប្រវត្តិសាស្ត្រជាមូលដ្ឋានដូចជា «ហេតុអ្វីបានជារបបខ្មែរក្រហមកើតឡើង?» «តើនរណាជាអ្នកកាន់អំណាចនៅក្នុងរបបខ្មែរក្រហម?» ដែលសំណួរទាំងនេះបានចង្អុលបង្ហាញពីកម្រិតនៃការយល់ដឹងពីរបបខ្មែរក្រហមក្នុងចំណោមអ្នករស់រានទាំងនោះ ។ អ្នកចូលរួមដទៃទៀតបានសួរសំណួរដែលពិបាកនឹងផ្តល់ចម្លើយ ដូចជា «ហេតុអ្វីបានជាប៉ុល ពត សម្លាប់មនុស្ស ប្រសិនបើគាត់មិនចង់ឲ្យប្រជាជនមានការលំបាក?» ឬ«ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់បញ្ញវន្តនៅពេលដែលមេដឹកនាំខ្មែរក្រហមមួយចំនួនសុទ្ធតែជាមនុស្សមានការអប់រំ?» ដែលទាមទារឲ្យមានការពិភាក្សាច្រើនទៅលើសំណួរទាំងនេះ ដើម្បីឈានទៅរកការទទួលបាននូវការដោះស្រាយដែលមិនលំអៀង ។ នៅក្នុងន័យនេះ ការបង្រៀនពីការសិក្សាអំពើប្រល័យពូជសាសន៍ មិនត្រឹមតែបានកំណត់ឲ្យអនុវត្តនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ ប៉ុន្តែគឺជាការខិតខំព្យាយាមដែលត្រូវតែធ្វើយ៉ាងណាឲ្យបានដល់សាលារៀនទាំងអស់ និងគ្រប់សហគមន៍ទាំងអស់ក្នុងប្រទេសកម្ពុជា ។ សម្រាប់ការអប់រំឲ្យមានប្រសិទ្ធិភាពវិញ គឺតម្រូវឲ្យមានការសហការណ៍ពីគ្រូបង្រៀន សិស្សានុសិស្ស ឪពុកម្តាយ មន្ត្រីរាជការ និងមនុស្សវ័យចំណាស់ ដើម្បីចូលរួមទាំងអស់គ្នាក្នុងដំណើរការមួយដែលត្រូវតែអនុវត្តចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ ក្នុងការប្រយុទ្ធប្រឆាំងដោយប្រយោលចំពោះភាពអមនុស្សធម៌ ។

វេទិកាសាធារណៈលើកដំបូងត្រូវបានប្រារព្ធធ្វើឡើងនៅភូមិអន្ទង់ជ្រៃ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ខាងក្រោមនេះគឺជាការអធិប្បាយពីសកម្មភាពនានារបស់វេទិកាសាធារណៈ ៖

## ការអធិប្បាយពីលក្ខណៈភូមិសាស្ត្រ និង សាលារៀន

វេទិកាសាធារណៈលើកដំបូង ត្រូវបានប្រារព្ធធ្វើឡើងនៅក្នុងវិទ្យាល័យ ហ៊ុន សែន អន្ទង់ជ្រៃ ស្ថិតក្នុងភូមិអន្ទង់ជ្រៃ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ វិទ្យាល័យនេះ មានទីតាំងស្ថិតនៅឆ្ងាយពីទីប្រជុំជនខេត្តកំពង់ស្ពឺប្រហែល៥២គីឡូម៉ែត្រ ។ ផ្លូវទៅកាន់ទីតាំងនេះមានភាពងាយស្រួលច្រើន ដោយសារមានការជួសជុលជាច្រើនដងក្នុងការសម្រួលដល់ការធ្វើដំណើរនិងដឹកជញ្ជូន ។ នៅក្នុងឆ្នាំ១៩៨១ វិទ្យាល័យនេះ ត្រូវបានកសាងឡើងនៅក្នុងទំហំដីចំនួន៧ហិកតា ដែលកាលនោះគឺជាអនុវិទ្យាល័យដំបូងបំផុតនៅក្នុងស្រុកថ្ពង ។ នៅឆ្នាំ ២០០៧ អនុវិទ្យាល័យនេះត្រូវបានប្រែក្លាយទៅជាវិទ្យាល័យវិញ ដែលមានអគារចំនួនប្រាំ រួមទាំងអគារទីចាត់ការមួយផង ។ វិទ្យាល័យនេះមាន២៨បន្ទប់ ដែលអាចដាក់សិស្សបានចំនួន៧៤៥នាក់ គ្រូចំនួន២៥នាក់ (ដែលក្នុងនោះមានគ្រូបង្រៀនប្រវត្តិវិទ្យាចំនួន៤នាក់ គ្រូអក្សរសាស្ត្រខ្មែរចំនួន៣នាក់ និងគ្រូសីលធម៌ពលរដ្ឋចំនួន៣នាក់ ដែលអ្នកទាំងនោះមិនទាន់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅឡើយទេ) និងបុគ្គលិករដ្ឋបាល ព្រមទាំងនាយកវិទ្យាល័យផង ។ សាលានេះបានផ្តល់នូវការអប់រំដល់សិស្សពីថ្នាក់ទី៧ដល់ទី១២ ។ ដោយសារតែវិទ្យាល័យនេះមានគ្រូបង្រៀនតិចតួច ទើបគ្រូមួយចំនួនទទួលភារកិច្ចបង្រៀនពីពីរទៅបីមុខវិជ្ជាម្នាក់ឯង ។

ដោយសារតែវិទ្យាល័យនេះស្ថិតនៅទីជនបទដាច់ស្រយាល ទើបមានការជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលជាគន្លឹះដ៏ចម្បងក្នុងការបង្កើនគុណភាពនៃការអប់រំ ។ ដីរាប់ម៉ឺនហិកតាបានក្លាយទៅជាដីសម្បទានសម្រាប់ក្រុមហ៊ុនឯកជន ។ សិស្សានុសិស្សមួយចំនួនបានគេចវេសសាលារៀន ដើម្បីទៅធ្វើការឲ្យក្រុមហ៊ុនក្នុងការរកប្រាក់ចំណូលបន្ថែមសម្រាប់ចិញ្ចឹមគ្រួសាររបស់ខ្លួន ។ ឪពុកម្តាយខ្លះបានជម្រុញឲ្យកូនៗបោះបង់ចោលការសិក្សា ហើយងាកមកជួយរកស៊ីគ្រួសារជំនួសវិញ ។ ឪពុកម្តាយទាំងនោះមានអារម្មណ៍ថា មិនមានបញ្ហាអ្វីទាំងអស់ចំពោះការសិក្សារបស់កូនៗ ហើយទីបំផុតកូនៗរបស់ខ្លួននៅតែជាអ្នកធ្វើស្រែដដែល ។ គាត់គិតទៀតថា វាគឺជាការចំណាយពេលវេលាឥតប្រយោជន៍ដែលឲ្យកូនៗរបស់គាត់បន្តការសិក្សាយូរពេកនៅក្នុងសាលារៀន ។ គ្រូដែលទើបផ្លាស់មកថ្មី មិនអាចស៊ូទ្រាំនឹងស្ថានភាពរស់នៅបានឡើយ ហើយអ្នកទាំងនោះបានសុំផ្លាស់ចេញជាបន្តបន្ទាប់ បន្ទាប់ពីគេបានបំពេញក្របខណ្ឌបង្រៀនរយៈពីរឆ្នាំរួចមក ដោយបន្សល់ទុកនូវគ្រូដែលមានសមត្ថភាពទន់ខ្សោយនិងបទពិសោធន៍តិចតួចឲ្យបង្រៀនសិស្សទៅវិញ ។

## ជួបប្រជុំជាមួយនាយកវិទ្យាល័យ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបណ្តុះបណ្តាលគ្រូថ្នាក់ខេត្តចំនួន១៨០នាក់ ដែលមកពីគ្រប់ស្រុកក្នុងទូទាំងប្រទេសកម្ពុជា ។ ដូច្នេះនៅក្នុងវេទិកានីមួយៗ យើងបានប្រាប់ឲ្យគ្រូថ្នាក់ខេត្តជួយធ្វើការទាក់ទងក្នុងការធ្វើវេទិកាសាធារណៈ ។ សមាជិកក្រុមការងាររបស់គម្រោងរួមមាន កញ្ញា លី សុខចំរើន លោក ឌី ខាំបូលី លោក ផេង ពង្សរ៉ាស៊ី លោក វ៉ាន់ថាន់ ពៅដារ៉ា និង លោក ប្រាក់ កែវដារ៉ា បានធ្វើដំណើរទៅកាន់ទីតាំងប្រារព្ធធ្វើវេទិកាសាធារណៈមុនមួយថ្ងៃ ដើម្បីរៀបចំទីកន្លែងនិងឧបករណ៍ផ្សេងៗ ក៏ដូចជាការពិភាក្សាពីការងារគម្រោងជាមួយនឹងមន្ត្រីពាក់ព័ន្ធមួយចំនួន ។ លោកគ្រូ ឃឹម វ៉ន ជាគ្រូបង្គោលថ្នាក់ខេត្តមកពីស្រុកថ្គង បានជួយក្រុមការងារយើងក្នុងការផ្តល់ដំណឹងទៅមន្ត្រីអប់រំស្រុកនិងនាយកសាលា ព្រមទាំងបានអញ្ជើញលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងឪពុកម្តាយរបស់សិស្ស ។ លោកគ្រូបានជួយក្នុងការប្រើប្រាស់ប្រភពធនធានដែលមានស្រាប់ និងបានកាត់បន្ថយការចំណាយផ្សេងៗដែលមិនចាំបាច់ក្នុងការរៀបចំធ្វើវេទិកាសាធារណៈនេះ ។

នៅថ្ងៃទី២២ ខែសីហា សមាជិកក្រុមការងារបានជួបជាមួយលោក មាស ធន ជានាយកវិទ្យាល័យ និងលោកគ្រូ ឃឹម វ៉ន ដើម្បីពិភាក្សាពីការងារសម្រាប់ថ្ងៃស្អែក ។ លោក មាស ធន បានប្រាប់ថា ខែសីហាគឺជាពេលវេលាវិស្សមកាលរបស់សិស្ស ។ មានតែសិស្សដែលមករៀនគួរបន្ថែមប៉ុណ្ណោះ ដែលអាចចូលរួមក្នុងវេទិកានេះបាន ។ លោក មាស ធន បានអញ្ជើញអ្នកភូមិមួយចំនួនដែលរស់នៅក្បែរៗវិទ្យាល័យឲ្យចូលរួម ប៉ុន្តែគាត់គិតថា មានតែអ្នកភូមិមួយចំនួនតូចប៉ុណ្ណោះដែលអាចបានមកចូលរួមបាន ពីព្រោះរដូវនេះគឺជារដូវវស្សា ហើយអ្នកភូមិភាគច្រើនបានយកឱកាសនេះទៅប្រកបរបរភ្ជួរស្រែនិងស្ទូងស្រូវ ។ ម្យ៉ាងវិញទៀត រដូវនេះក៏ជារដូវដែលប្រជាជនខ្មែរកាត់ចិនមួយចំនួនត្រូវប្រារព្ធធ្វើពីធីបុណ្យសែនផ្នូរ (ឆេងម៉េង)ផង ។

## បើកកម្មវិធី

លោក ផេង ពង្សរ៉ាស៊ី បានបើកកម្មវិធី និងបានប្រកាសពីកម្មវិធីសម្រាប់ថ្ងៃនេះ ព្រមទាំងបានចាប់ផ្តើមដោយមានការអធិប្បាយដោយសង្ខេបពីគោលបំណងនៃការធ្វើវេទិកាសាធារណៈ ដោយ លោក ឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការឡើងមានមតិដោយអ្នកតំណាងមន្ត្រីអប់រំស្រុកផង ។ បូលី បានបញ្ជាក់ពីកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើពិធីចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងវគ្គបណ្តុះបណ្តាលគ្រូ ដែលជាផ្នែកមួយនៃគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ បូលី បានអធិប្បាយពីសារៈសំខាន់នៃការធ្វើវេទិកាសាធារណៈថា ជាការសិក្សាពីអំពើប្រល័យពូជសាសន៍ក្រៅផ្លូវការមួយ ព្រមទាំងបានប្រាប់ពីគោលបំណងនៃការធ្វើវេទិកានេះ ។ បូលី បាននិយាយថា វេទិកាសាធារណៈនេះមានសារៈសំខាន់ណាស់ដែលលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស អ៊ំ ពូ មីង ដែលជាឪពុកម្តាយរបស់សិស្ស អាចមានឱកាសមកអង្គុយនៅក្នុងបន្ទប់តែមួយ និងទទួលបាននូវការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ ការនិយាយបែបនេះ នឹងអនុញ្ញាតិឲ្យអ្នកចូលរួមទាំងអស់

ស្វែងយល់ពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រក្នុងពេលតែមួយ ។ ការសហការរវាងក្មេងជំនាន់ក្រោយ និង មនុស្សចាស់ដែលជាសាក្សីផ្ទាល់នៃអំពើដ៏ឃោរឃៅ ត្រូវតែបានលើកទឹកចិត្ត ។ គ្រូបង្រៀនជាអ្នកដើរតួយ៉ាង សំខាន់ក្នុងការសម្របសម្រួល ដើម្បីធានាថាកិច្ចពិភាក្សានេះពិតជាកើតមាននៅក្នុងគ្រួសារនិងសហមគមន៍ភាគ ច្រើន ហើយថាសិស្សានុសិស្សគឺជាផ្នែកមួយនៅក្នុងដំណើរការនេះដែរ ដើម្បីឈានដល់ការព្យាបាលរបួសផ្លូវចិត្ត និងការផ្សះផ្សា ។

អ្នកចូលរួមនៅក្នុងវេទិកានេះមានសិស្សានុសិស្សចំនួន៨៥នាក់ ដែលជាសិស្សកំពុងសិក្សានៅថ្នាក់ទី១០ និងទី១២ អ្នកភូមិចំនួន៦នាក់ និងគ្រូចំនួន២នាក់ ។ ដោយសារតែវេទិកាសាធារណៈនេះបានត្រូវធ្វើឡើងនៅ ក្នុងពេលវិស្សមកាល សិស្សានុសិស្សទាំងអស់បានស្លៀកសំលៀកបំពាក់ធម្មតាមកចូលរួមក្នុងវេទិកា ដោយមិន មានប៊ិច និងក្រដាសមកជាមួយឡើយ ។ សំណួរមួយត្រូវបានសួរថា តើអ្នកទាំងអស់គ្នាបានសិក្សាពីប្រវត្តិ សាស្ត្រខ្មែរក្រហមនៅក្នុងថ្នាក់រៀនពីមុនមកទេ? សិស្សខ្លះបានឆ្លើយថាបានរៀនខ្លះៗដែរ ។ ដោយស្តាប់ឮថា ប្រវត្តិសាស្ត្រខ្មែរក្រហមបានចេញប្រឡងនៅក្នុងការប្រឡងបាក់ឌុបពីរដងរួចមកហើយគឺក្នុងឆ្នាំ២០០៩ និងឆ្នាំ ២០១០ និងបានចេញប្រឡងឆមាសចំនួនពីរដងដែរនោះ សិស្សបានចាប់ផ្តើមចាប់អារម្មណ៍ពីអ្វីដែលក្រុមការ ងារបាននិងកំពុងធ្វើនៅក្នុងការធ្វើវេទិកានេះ ហើយបានចែករំលែកក្រដាស ប៊ិច និង ខ្មៅដៃ ដើម្បីកត់ត្រា ។

## សកម្មភាពនៃការធ្វើវេទិកា

### ១) ការធ្វើបទបង្ហាញជំពូកទី៨៖ ប្រព័ន្ធសន្តិសុខ ដោយលោក ផេង ពង្សរ៉ាស៊ី

លោក ផេង ពង្សរ៉ាស៊ី បានចាប់ផ្តើមបទបង្ហាញដោយការសួរពីអត្ថន័យនៃពាក្យ "សន្តិសុខ" ។ រ៉ាស៊ី បានចោទសួរសិស្សពីចំណេះដឹងស្តីអំពីការឡើងកាន់អំណាច និងការដួលរលំរបស់ខ្មែរក្រហម ។ សិស្សម្នាក់ បានក្រោកឈរឡើងហើយនិយាយថា *"របបខ្មែរក្រហមបានកើតឡើងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង បានដួលរលំទៅវិញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩"* ។ បន្ទាប់មក រ៉ាស៊ី បានបន្តពន្យល់ពីប្រព័ន្ធសន្តិសុខ ទាំងប្រាំថ្នាក់របស់ខ្មែរក្រហម ដែលរួមមានមន្ទីរសន្តិសុខថ្នាក់មជ្ឈឹម "មន្ទីរស-២១" មន្ទីរសន្តិសុខថ្នាក់ភូមិភាគ មន្ទីរសន្តិសុខថ្នាក់តំបន់ និងមន្ទីរសន្តិសុខថ្នាក់ស្រុក និងថ្នាក់ឃុំ ព្រមទាំងបានពន្យល់ពីប្រភេទអ្នកទោសដែលត្រូវ ចាប់និងឃុំខ្លួន ។ អ្នកទោសភាគច្រើននៃមន្ទីរសន្តិសុខមជ្ឈិម គឺជាអ្នកទោសនយោបាយដែលជាកម្មាភិបាលរបស់ ខ្មែរក្រហម ។ ចំណែកអ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខថ្នាក់ក្រោមៗ គឺមានរាប់បញ្ចូលទាំងអតីត មន្ត្រីរដ្ឋការចាស់ និងមន្ត្រីយោធានៃរបប លន់ នល់ និង របបសីហនុ ។ រ៉ាស៊ី បានផ្តល់ឧទាហរណ៍ពីវិធីដែល ខ្មែរក្រហមធ្វើការកត់សម្គាល់មនុស្សដែលជាអតីតមន្ត្រីរដ្ឋការចាស់ ។ ឧទាហរណ៍ ខ្មែរក្រហមបានប្រកាសនៅក្នុង ខេត្តបាត់ដំបងថា អ្នកដែលធ្លាប់ធ្វើជាមន្ត្រីយោធានៃរបប លន់ នល់ គួរតែមកចុះឈ្មោះនៅក្នុងតារាងពិសេស ដើម្បីត្រឡប់ចូលកាន់តំណែងដូចដើមវិញ ។ មន្ត្រីយោធាទាំងអស់ដែលបានចុះឈ្មោះត្រូវបានសម្លាប់ចោលជា ទ្រង់ទ្រាយធំ ។ បន្ទាប់មក រ៉ាស៊ី បានពន្យល់ពីរបៀបដែលខ្មែរក្រហមធ្វើខ្នោះដៃ និងខ្នោះជើង ។ រ៉ាស៊ី បានធ្វើ

សេចក្ដីសង្ខេបទៅលើជំពូកទាំងមូល ដោយរៀបរាប់ថា ខ្មែរក្រហមបានបែងចែកខ្មាំងជាពីរប្រភេទគឺ ខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ ។ រ៉ាស៊ី បានចោទសួរទៅកាន់អ្នកចូលរួមទាំងអស់ថា តើមានស្គាល់មនុស្សនៅក្នុងប្រភេទខ្មាំងទាំងពីរនេះដែរឬទេ ។

## ២) សំណួរពីអ្នកចូលរួម

នៅចុងបញ្ចប់នៃការធ្វើបទបង្ហាញ រ៉ាស៊ី បានបើកឲ្យមានការសួរសំណួរពីអ្នកចូលរួមទាំងអស់ ។ បូលី និង ដារ៉ា បានជួយ រ៉ាស៊ី ក្នុងការឆ្លើយសំណួរ ហើយសំណួរទាំងអស់ពីអ្នកចូលរួមមានដូចខាងក្រោមៈ

១. ហេតុអ្វីបានជាកើតមានរបបខ្មែរក្រហមឡើង?

២. ខ្មែរក្រហមចង់បង្កើតសង្គមមួយដែលគ្មានភាពក្រីក្រ គ្មានអំពើពុករលួយ និងជាកន្លែងដែលមនុស្សគ្រប់គ្នាអាចរស់នៅស្មើភាពគ្នា និងសប្បុរសប្បាយ ។ ហេតុអ្វីបានជា ប៉ុល ពត សម្លាប់ប្រជាជន ប្រសិនបើខ្លួនមិនចង់ឲ្យប្រជាជនត្រូវគេជិះជាន់?

៣. តើនរណាជាអ្នកកាន់អំណាចនៅក្នុងរបបខ្មែរក្រហម?

៤. តើរបបខ្មែរក្រហមនឹងកើតឡើងម្ដងទៀតទេ?

៥. ឪពុកម្ដាយខ្ញុំបានប្រាប់ខ្ញុំថា ខ្មែរក្រហមបានផលិតស្រូវយ៉ាងច្រើន ។ ប៉ុន្តែប្រជាជនបានជួបគ្រោះអត់ឃ្លាននៅពេលនោះ ។ តើខ្មែរក្រហមយកស្រូវទាំងអស់នោះទៅណា? ហេតុអ្វីបានជាខ្មែរក្រហមមិនអនុញ្ញាតឲ្យប្រជាជនហូបឲ្យបានគ្រប់គ្រាន់?

៦. ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់បញ្ញវន្ត បើមេដឹកនាំខ្មែរក្រហមមួយចំនួនជាអ្នកមានចំណេះដឹង?

រ៉ាស៊ី បានឆ្លើយសំណួរទី៤យ៉ាងច្បាស់លាស់ទៅកាន់អ្នកចូលរួមថា «យើងមិនចង់ឲ្យអំពើប្រល័យពូជសាសន៍កើតឡើងនៅលើទឹកដីយើងម្ដងទៀតទេ ។ នេះជាមូលហេតុដែលយើងនៅទីនេះជាមួយគ្នាក្នុងថ្ងៃនេះ» ។

## ៣) ប្រតិកម្មរបស់អ្នកចូលរួម

នៅពេលដែលសួរថា តើមានបានឮអ្វីផ្សេងទៀតពីរបបខ្មែរក្រហមដែរទេ? ក្មេងៗភាគច្រើនបានបង្ហាញនូវភាពវិជ្ជមាន ។ អ្នកទាំងនោះបានស្ដាប់ឮរឿងរ៉ាវទាំងនេះពីឪពុកម្ដាយខ្លួននិងបានរៀនពីសាលារៀន ។ នៅពេលដែលមាននរណាម្នាក់សួរសំណួរថា «តើអ្នកគិតអ្វីមុនគេ នៅពេលអ្នកនិយាយពីរបបខ្មែរក្រហម?» សិស្សមួយចំនួនបានឆ្លើយថា ការសម្លាប់ ការបង្ខំធ្វើការហួសកម្លាំង បង្អត់អាហារ ការជម្លៀស និង ការបំបែកគ្រួសារ ។ គ្រូម្នាក់បាននិយាយថា គាត់បានឆ្លងកាត់របបខ្មែរក្រហមដោយផ្ទាល់ ប៉ុន្តែគាត់បានចងចាំនូវរឿងរ៉ាវខ្លះៗប៉ុណ្ណោះ ហើយគាត់មិនអាចរំឭកឡើងវិញនូវទិដ្ឋភាពធំៗនៃរបបខ្មែរក្រហមបានទេ ។ ឧទាហរណ៍ គាត់មិនបានដឹងពីចម្លើយដែលឆ្លើយទៅនឹងសំណួរស្ដីពីចំនួនភូមិភាគក្នុងរបបកម្ពុជាប្រជាធិតេយ្យ ដែលបានចេញក្នុងការប្រឡងបាក់ឌុបបានឡើយ ។ គ្រូក៏បានសង្កត់ធ្ងន់ទៀតថា វាមានសារសំខាន់ណាស់ដែលប្រវត្តិសាស្ត្រខ្មែរក្រហមត្រូវបានចងក្រងទុកជាឯកសារបានយ៉ាងល្អ ។

នៅរសៀលថ្ងៃដដែល ក្រុមការងារបានធ្វើបទសម្ភាសន៍ជាមួយអ្នកភូមិ គ្រូបង្រៀន និងសិស្សានុសិស្ស ដើម្បីចង់ដឹងពីទស្សនៈរបស់អ្នកទាំងនោះទាក់ទងទៅនឹងការបង្រៀន *“ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ”*។ ខាងក្រោមនេះ គឺជាការដកស្រង់ចេញពីការធ្វើបទសម្ភាសន៍៖

ភឿ ស្រីនួន អាយុ១៨ឆ្នាំ ជាសិស្សមកពីសាលា ហ៊ុន សែន អន្លង់ជ្រៃ។ ឪពុកម្តាយរបស់នាងជាកសិករនៅភូមិត្រាំងវែង ឃុំប្រាំបីមុំ ស្រុកថ្ពង។ នាងមានបងប្អូនបង្កើត៥នាក់។ បន្ថែមទៅលើការសិក្សារបស់នាង នាងបានជួយធ្វើស្រែចម្ការ និងចិញ្ចឹមជ្រូក។ ស្រីនួន បានយល់ច្រើនអំពីខ្មែរក្រហម បន្ទាប់ពីបានចូលរួមក្នុងវេទិកាសាធារណៈនេះ។ នាងធ្លាប់បានឃើញទស្សនាវដ្តី“ស្វែងរកការពិត” ប៉ុន្តែនាងមិនបានយកចិត្តទុកដាក់អានវាទេ។ នៅក្នុងថ្នាក់រៀន ស្រីនួន សិក្សាអំពីសង្គ្រាមលោកលើកទី២ និងរបប លន់ នល់ ប៉ុន្តែនាងមិនបានរៀនច្រើនពីរបបខ្មែរក្រហមឡើយ។ មានពេលខ្លះឪពុកម្តាយនាងបាននិយាយឲ្យនាងស្តាប់អំពីបទពិសោធន៍របស់គាត់ឆ្លងកាត់របបខ្មែរក្រហម។ នាងបានដឹងថា ម្តាយរបស់នាងគឺជាអ្នកស្រុកមកពីក្នុងខេត្តតាកែវ ហើយត្រូវខ្មែរក្រហមជម្លៀសមកកាន់ខេត្តកំពង់ស្ពឺក្នុងរបបខ្មែរក្រហម។ ម្តាយរបស់នាងបានរស់នៅទីនេះចាប់តាំងពីពេលនោះមក។ ក្នុងរបបខ្មែរក្រហម ម្តាយនាងត្រូវបានបង្ខំឲ្យវែកដីធ្វើទំនប់។ នៅពេលដែលសួរនាងថា តើនាងចង់រៀនពីរបបខ្មែរក្រហមទេ នាងនិយាយថា *“ប្រសិនបើមាននរណាម្នាក់ប្រាប់ខ្ញុំ ខ្ញុំចង់ដឹង។ ប្រសិនបើមិនមានការអប់រំពីប្រវត្តិសាស្ត្រនោះទេ ខ្ញុំក៏មិនខ្វល់ដែរ”*។ ក្នុងគំនិតរបស់នាងវិញ ពាក្យថារបបខ្មែរក្រហម មានន័យថា ការសម្លាប់ និងគ្មានការអភិវឌ្ឍន៍។ នាងយល់ថា របបខ្មែរក្រហមគឺជារបបដែលឃោរឃៅបំផុត។ នាងបាននិយាយដូច្នេះថា *“វាពិតជាខុសប្លែកគ្នាខ្លាំងណាស់ពីសង្គមសព្វថ្ងៃ”*។ ឪពុករបស់នាងបានលើកទឹកចិត្តនាងឲ្យរៀនសូត្រ ដោយបានប្រាប់ថា គាត់គ្មានឱកាសបានរៀនសូត្រទេកាលពីជំនាន់ដែលគាត់រស់នៅ។ *“ឥឡូវកូនមានសាលារៀនក្បែរផ្ទះ”*។ ផ្ទះរបស់ស្រីនួនស្ថិតនៅក្បែរផ្ទះរបស់បុរសម្នាក់ដែលជាអតីតកម្មាភិបាលខ្មែរក្រហមដ៏កាចសាហាវម្នាក់ ដែលបានស្លាប់កាលពីប៉ុន្មានឆ្នាំមុនដោយសារជំងឺ។ ស្រីនួន មិនមានអារម្មណ៍ស្អប់ខ្ពើមចំពោះកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមទេ។ នាងបាននិយាយថា *“គាត់បានធ្វើអំពើអាក្រក់ច្រើនណាស់ ប៉ុន្តែកូនរបស់គាត់មិនបានប្រព្រឹត្តនូវកំហុសផ្សេងៗដូចជាឪពុករបស់គេបានធ្វើនោះទេ”*។ ម្យ៉ាងវិញទៀត កម្មាភិបាលខ្មែរក្រហមបានប្រព្រឹត្តបទឧក្រិដ្ឋកម្មទាំងអស់នោះ ពីព្រោះតែគាត់ត្រូវបានគេបញ្ជាឲ្យធ្វើដែរ”។ ស្រីនួន បាននិយាយថា នាងរាប់អានជាមួយកូនរបស់អតីតកម្មាភិបាលខ្មែរក្រហមជាធម្មតា។ បើទោះបីជាកម្មាភិបាលខ្មែរក្រហមបានសម្លាប់សាច់ញាតិបងប្អូនរបស់នាងក៏ដោយ ក៏នាងបាននិយាយថា នាងនៅតែនិយាយជាមួយកូនរបស់គាត់ដូចធម្មតា ប៉ុន្តែផ្ទុយទៅវិញ នាងមិនអាចនិយាយជាមួយនឹងជនដៃដល់ទេ។

ឃឹម វ៉ៃន ជាគ្រូបង្រៀននៅអនុវិទ្យាល័យ រស់នៅភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ លោកគ្រូបានចាប់អារម្មណ៍បង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមដោយសារមូលហេតុសំខាន់ពីរគឺ៖ ទី១) លោកគ្រូគឺជាគ្រូប្រវត្តិសាស្ត្រស្រាប់ និងទី២) លោកគ្រូចង់បង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដូច្នេះក្មេងជំនាន់ក្រោយអាចដឹង

ដើម្បីជៀសវាងកំហុសឆ្គងដដែលៗដែលបានកើតមាននៅក្នុងជំនាន់របស់គាត់ ។ គាត់បាននិយាយថា នៅពេលដែលសិស្សបានក្លាយទៅជាអ្នកដឹកនាំសង្គម ហើយមានចំណេះដឹងពីរបបខ្មែរក្រហមដូច្នេះ គឺនឹងជួយការពារអ្នកទាំងនោះពីការប្រព្រឹត្តិអំពើដដែលៗដូចរបបខ្មែរក្រហមទៀត ។ វ៉ន គិតថាប្រវត្តិសាស្ត្រខ្មែរក្រហមគឺខុសពីប្រវត្តិសាស្ត្រដ៏ទៃទៀត ។ គាត់ចង់ឲ្យសិស្សានុសិស្សបានដឹងពីប្រវត្តិសាស្ត្រទាំងមូលក្នុងរបបខ្មែរក្រហម និងការដួលរលំនៃរបបនេះនៅក្នុងជំពូក១១ ។ គាត់បាននិយាយថា គាត់នឹងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីអប់រំសិស្សានុសិស្ស ពីព្រោះអ្វីដែលខ្មែរក្រហមបានធ្វើគឺប្រឆាំងនឹងទស្សនៈរបស់ប្រជាជន ។ មកទល់សព្វថ្ងៃនេះគាត់នៅតែរំឭកពីបទពិសោធន៍របស់គាត់ក្នុងរបបខ្មែរក្រហម ។ ជាពិសេសគាត់បាននិយាយពីការលំបាករបស់ម្តាយគាត់ដែលបានជួបប្រទះអំឡុងពេលនោះ ។ “ម្តាយខ្ញុំបានក្រោកពីព្រលឹមរាល់ថ្ងៃ ហើយបានដើរទៅកាន់ភូមិផ្សេងទៀតដែលមានចម្ងាយប្រហែល២០គីឡូម៉ែត្រ ។ ម្តាយរបស់ខ្ញុំត្រូវបានបញ្ជាឲ្យភ្ជួរដី ដែលជាការងាររបស់មនុស្សប្រុស ។ គាត់ត្រូវបានផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងរយៈពេលកន្លះខែម្តង ។ ការធ្វើដំណើរតែងតែធ្វើឡើងនៅពាក់កណ្តាលអធ្រាតដើម្បីចំណេញពេលវេលា ។ បងប្អូនរបស់ខ្ញុំត្រូវបានបំបែកចេញពីគ្នា ។ ម្តាយរបស់ខ្ញុំបានយំ នៅពេលដែលគាត់រំឭករឿងរ៉ាវនេះឡើងវិញ” ។ វ៉ន មានការសោកស្តាយជាខ្លាំងដែលរបបនេះបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ វ៉ន បាននិយាយថា គាត់មិនអាចអត់ឱនឲ្យមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមដែលអំពើឧក្រិដ្ឋរបស់អ្នកទាំងនោះមិនអាចទទួលយកបានពីសំណាក់សហគមន៍ជាតិ និងអន្តរជាតិឡើយ ។ ទោះជាយ៉ាងដូច្នេះក៏ដោយ វ៉ន បាននិយាយថា គាត់អាចអត់ឱនឲ្យកម្មាភិបាលថ្នាក់ក្រោមដែលធ្វើតាមតែបញ្ជារបស់គេ ។ វ៉ន ជឿជាក់ថា ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យ គឺពិតជាសំខាន់ណាស់ ។ ក្មេងៗត្រូវតែទទួលបានការអប់រំមិនឲ្យគិតពីការសងសឹក ប៉ុន្តែឲ្យមានការអាណិតអាសូរចំពោះគ្នាទៅវិញទៅមក ។ គាត់ជឿជាក់ថា ការបង្រៀននឹងនាំដល់វិសាលភាពនៃការផ្សះផ្សាជាតិ និងព្យាបាលរបួសផ្លូវចិត្ត ។ គាត់បាននិយាយថា “យើងត្រូវតែយល់ជាមុនសិន មុននឹងឈានដល់ការផ្សះផ្សាគ្នា” ។ ការរើសអើងគឺនៅតែកើតមាននៅក្នុងភូមិរបស់គាត់នៅឡើយ ។ យោងតាមបទពិសោធន៍របស់គាត់ដែលធ្លាប់បង្រៀនសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម សិស្សមានការសប្បាយរីករាយ និងចាប់អារម្មណ៍ចំពោះប្រវត្តិសាស្ត្រខ្មែរក្រហម ប៉ុន្តែសិស្សទាំងនោះបានធ្វើការប្រៀបធៀបអំពីអំពើព្រៃផ្សៃនៃរបបនេះ ទៅនឹងអំពើព្រៃផ្សៃដែលកើតឡើងនៅប្រទេសដទៃទៀត ។ សិស្សជឿជាក់ថា ការសម្លាប់ និងការធ្វើទារុណកម្មនៅក្នុងប្រទេសកម្ពុជាគឺមានលក្ខណៈឃោរឃៅជាងប្រទេសដទៃ ។ សិស្សម្នាក់ក្នុងចំណោមសិស្សទាំងអស់របស់គាត់បាននិយាយថា “ប្រសិនបើខ្ញុំក្លាយជាអ្នកដឹកនាំនៅពេលអនាគត ខ្ញុំនឹងលើកកម្ពស់ឲ្យមានការបង្រៀនប្រវត្តិសាស្ត្រឲ្យបានត្រឹមត្រូវ ។ ខ្ញុំនិងមិនដើរតាមផ្លូវដែលខ្មែរក្រហមដើរនោះទេ” ។

ប៉ែន សាន់ អាយុ៦៤ឆ្នាំ ជាអ្នកភូមិអូរអង្គំ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ នៅក្នុងរបបខ្មែរក្រហម គាត់ធ្វើការនៅក្នុងកងចល័តដែលផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត ។ គាត់ត្រូវបានទទួលបញ្ជាឲ្យ

លើទំនប់និងជីកប្រឡាយ ។ គាត់ធ្លាប់ធ្វើគ្រូបង្រៀននៅសាលាបឋមសិក្សាអស់រយៈពេល២៨ឆ្នាំ ។ គាត់ទើបតែចូលនិវត្តន៍បាន៤ឆ្នាំប៉ុណ្ណោះ ។ នៅពេលដែលគាត់នៅជាគ្រូបង្រៀន ជានិច្ចកាលគាត់បានប្រាប់សិស្ស និងកូនៗរបស់គាត់អំពីជីវិតរស់នៅក្រោមរបបខ្មែរក្រហម និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ។ គាត់ចង់ឲ្យកូនៗរបស់គាត់ និងអ្នកដទៃទៀតបានដឹងពីការឈឺចាប់របស់ប្រជាជនកម្ពុជានាពេលនោះ និងដឹងនូវអ្វីដែលខ្មែរក្រហមបានធ្វើមកលើប្រជាជនកម្ពុជា ។ នេះជាការសំខាន់ណាស់សម្រាប់ក្មេងជំនាន់ក្រោយក្នុងការស្វែងយល់ពីប្រវត្តិសាស្ត្រនេះ ដើម្បីឲ្យពួកគេចេះគិតពិចារណាឲ្យស៊ីជម្រៅអំពីការឈឺចាប់របស់ឪពុកម្តាយខ្លួន ។ និយាយអំពីរបបខ្មែរក្រហម គាត់បានរំឭកឡើងវិញពីការសម្លាប់ ការធ្វើការហួសកម្លាំង និងកង្វះខាតម្ហូបអាហារ ។ នៅពេលដែលគាត់កំពុងឡើងយកទឹកត្នោត គាត់បានឃើញខ្មែរក្រហមបណ្តើរមនុស្សទាំងខ្សែរៗទៅសម្លាប់ ។ គាត់តែងតែរៀបរាប់ពីប្រវត្តិរបស់គាត់ក្នុងរបបខ្មែរក្រហមឲ្យកូនចៅរបស់គាត់ស្តាប់ បន្ទាប់ពីទទួលទានអាហារពេលល្ងាចក្នុងពេលដែលក្រុមគ្រួសារនិយាយជជែកគ្នាលេង ។ គាត់មិនហ៊ានធានាថា កូនគាត់ជឿនូវអ្វីដែលគាត់បាននិយាយប្រាប់ពួកគេដែរ ។ ប៉ុន្តែក៏មិនមាននរណាម្នាក់និយាយថា «ខ្ញុំមិនជឿ»នោះដែរ ។ ផ្ទុយទៅវិញក្មេងៗទាំងនោះមានអារម្មណ៍អាណិតអាសូរដល់ឪពុកម្តាយខ្លួន និងអ្នកដែលមានបទពិសោធន៍ឆ្លងកាត់ការពិបាក ។ គាត់ជឿជាក់ថា ប្រវត្តិសាស្ត្រខ្មែរក្រហមគួរតែត្រូវបានបង្រៀននៅក្នុងសាលារៀន ដើម្បីថែរក្សាការចងចាំដែលអំពើឃោរឃៅនឹងមិនអាចកើតឡើងជាលើកទីពីរបានឡើយ ។ សម្រាប់គាត់វិញ ការសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនឹងនាំមកនូវការអត់ឱនដែលគ្មានការបែងចែក ។ គាត់រស់នៅក្បែរគ្នាជាមួយអតីតកម្មាភិបាលខ្មែរក្រហម ។ ទោះជាយ៉ាងនេះក៏ដោយ ការរស់នៅរបស់ពួកគាត់គឺធម្មតា ពីព្រោះកម្មាភិបាលធំៗរបស់ខ្មែរក្រហមដែលរស់នៅក្នុងភូមិបានស្លាប់ជាយូរយារណាស់មកហើយ ។ គាត់មិនមានការរើសអើងជាមួយកូនរបស់ជនដៃដល់ទេ ហើយពួកគេនៅតែលេងជាមួយគ្នាជាធម្មតា ។

## តារាង: បញ្ជីឈ្មោះអ្នកត្រូវបានសម្ភាស

| ល.រ | ឈ្មោះ | ភេទ | មុខងារ | អាស័យដ្ឋាន |
|---|---|---|---|---|
| ១ | ភឿន ស្រីនួន | ស្រី | សិស្ស | ភូមិត្រាំវែង ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ២ | យាង យុទ្ធា | ប្រុស | សិស្ស | ភូមិអន្លង់ជ្រៃ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៣ | ដៃ វីន | ប្រុស | សិស្ស | ភូមិចំបក់ធំ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៤ | កែវ សុខម | ស្រី | សិស្ស | ភូមិអូរអង្គ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៥ | ដែន សាន់ | ប្រុស | ឪពុក | ភូមិអូរអង្គ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៦ | ទុយ សាវរី | ស្រី | សិស្ស | ភូមិស្នួល ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |
| ៧ | ទឹម វ៉ន | ប្រុស | គ្រូ | ភូមិថ្មី ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |

| | | | | |
|---|---|---|---|---|
| ៨ | អ៊ុំ វ៉ា | ប្រុស | ឪពុក | ភូមិអូរអង្គ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ |

## ឧបសគ្គ

ការអញ្ជើញអ្នកចូលរួមឲ្យមកចូលរួមវេទិកាសាធារណៈ គឺជាជំហានដំបូងដ៏សំខាន់ដើម្បីធានាពីភាពជោគជ័យនៃការធ្វើវេទិកានេះ ។ អ្នកចូលរួមទាំងអស់ត្រូវតែទទួលបានដំណឹងឲ្យបានច្បាស់លាស់ពីរបីថ្ងៃមុនពេលចាប់ផ្តើមធ្វើវេទិកា ។ អ្នកទាំងនោះត្រូវតែមានការលើកទឹកចិត្ត និងមានលទ្ធភាពក្នុងការស្វែងយល់ពីតម្លៃនៃការចូលរួមនៅក្នុងវេទិកា ។ ដោយសារតែក្រុមការងារមិនបានស្ថិតនៅទីកន្លែងដែលត្រូវប្រារព្ធធ្វើវេទិកាសាធារណៈដោយផ្ទាល់ ដូច្នេះអ្នកផ្តល់ដំណឹងដ៏សំខាន់ គឺជាគ្រូថ្នាក់ខេត្តនិងអាជ្ញាធរដែនដី ដែលជួយក្នុងការអញ្ជើញអ្នកភូមិដែលកូនចៅរបស់គាត់កំពុងតែសិក្សានៅក្នុងសាលារៀន ឬអ្នកភូមផ្សេងទៀត ។ នៅក្នុងការធ្វើវេទិកាសាធារណៈដំបូងនេះ នាយកវិទ្យាល័យ និងគ្រូថ្នាក់ខេត្តមានលទ្ធិភាពអញ្ជើញអ្នកភូមិបានតែប្រាំមួយនាក់ប៉ុណ្ណោះ ។ ក្រៅពីនេះគឺសុទ្ធតែសិស្សានុសិស្សដែលមករៀនបន្ថែមក្នុងពេលវិស្សមកាល ។ ដើម្បីដោះស្រាយឧបសគ្គនេះ សមាជិកក្រុមការងារគួរតែទាក់ទងជាមួយគ្រូថ្នាក់ខេត្ត និងជាពិសេសជាមួយនិងអាជ្ញាធរដែនដីដែលមានទំនាក់ទំនងជាមួយយើងក្នុងការជួយអញ្ជើញអ្នកភូមិដែលអ្នកទាំងនោះគឺជាទិសដៅរបស់គម្រោង ។ ក្រុមការងារត្រូវតែពន្យល់អ្នកផ្តល់ព័ត៌មានទាំងពីរនាក់ឲ្យបានច្បាស់អំពីគោលបំណង និងវត្ថុបំណងនៃការធ្វើវេទិកាសាធារណៈនេះ ។ អ្នកភូមិត្រូវតែមើលឃើញពីតម្លៃនៃការចូលរួមនៅក្នុងវេទិកាសាធារណៈ ជាជាងគ្រាន់តែមកចូលរួមធម្មតា ។ វេទិកាសាធារណៈគឺជាការសិក្សាក្រៅផ្លូវការពីអំពើប្រល័យពូជសាសន៍ ដូច្នេះចំនួនអ្នកចូលរួមគួរតែរៀបចំពី៧០នាក់ដល់២០០នាក់ ហើយកន្លែងដែលប្រារព្ធធ្វើវេទិកាគួរតែរៀបចំនៅកន្លែងផ្សេងក្រៅពីសាលារៀន ។

## ការធ្វើបទបង្ហាញ :

ការធ្វើបទបង្ហាញពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គួរតែត្រូវបានរៀបចំឲ្យបានល្អ ជាជាងការដោយជ្រើសរើសដោយចៃដន្យក្នុងចំណោមមេរៀនទាំង១១ជំពូកនៅក្នុងសៀវភៅ ។ ក្រុមការងារត្រូវតែមានភាពច្បាស់លាស់ពីការយល់ដឹងនូវអ្វីដែលខ្លួនចង់សម្រេចបាននៅចុងបញ្ចប់នៃវេទិកា ។ ប្រធានបទសម្រាប់ធ្វើបទបង្ហាញ គួរតែត្រូវបានជ្រើសរើសដោយផ្អែកទៅលើទីតាំងនៃការធ្វើវេទិកា ។ ឧទាហរណ៍ បទបង្ហាញទៅលើ «ការធ្វើបន្សុតកម្មនៅក្នុងភូមិភាគបូព៌ា» គួរតែធ្វើនៅក្នុងខេត្តព្រៃវែង ។ អ្នកធ្វើបទបង្ហាញត្រូវតែអភិវឌ្ឍជំហាននៃការធ្វើបទបង្ហាញរបស់ខ្លួន តាមវិធីសាស្ត្រដែលមាននៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន ដែលបង្កើតឲ្យមានការត្រិះរិះពិចារណាយ៉ាងស៊ីជម្រៅ ។ ជាងនេះទៅទៀត ដើម្បីបង្កើតនូវសកម្មភាពនៃការពិភាក្សា អ្នកចូលរួមគួរតែមានឱកាសបន្ថែមក្នុងការនិយាយ និងចូលរួមនៅក្នុងការអាននិងការពិភាក្សា ។ កិច្ចសន្ទនាក្នុងចំណោមអ្នកភូមិ គ្រូបង្រៀន និង សិស្សានុសិស្ស នឹងបង្កើតឲ្យមានការពិភាក្សបន្ថែមទៀតនៅតាមផ្ទះ បន្ទាប់ពីបញ្ចប់វេទិកានេះ ។ នៅក្នុងន័យនេះ យើងអាចបែងចែកអ្នកចូលរួមជាក្រុម និងឲ្យអានមេរៀនជាផ្នែកៗ

ដើម្បីជាមូលដ្ឋានក្នុងការធ្វើការពិភាក្សា ។ ដើម្បីដោះស្រាយជាមួយបញ្ហានេះ សមាជិកក្រុមការងារដែលនឹងត្រូវធ្វើបទបង្ហាញឬបង្រៀន ត្រូវតែរៀបចំកិច្ចតែងការបង្រៀនជាមុន និងនាំយកសម្ភារៈសម្រាប់បង្រៀនពីការិយាល័យឲ្យបានគ្រប់គ្រាន់ ។ វាមានសារសំខាន់ណាស់ដើម្បីធានាថា កម្មវិធីសម្រាប់ការធ្វើវេទិកាសាធារណៈនេះ គឺជាការអនុវត្តន៍ មានការរៀបចំ និងសម្របសម្រួលឲ្យបានល្អ ។

## លទ្ធិផល និង ការសង្កេតទូរទៅ

វេទិកាសាធារណៈស្តីពីការអប់រំប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកភូមិនៅក្នុងសហគមនានាដើម្បីមកចូលរួមក្នុងដំណើរការនេះ ។ វេទិកានេះនាំមកនូវចំណេះដឹងអំពីសារសំខាន់នៃការសិក្សាពីអំពើប្រល័យពូជសាសន៍ដល់សហគមន៍ ដោយលើកទឹកចិត្តឲ្យមានការពិភាក្សារវាងអ្នកភូមិ មនុស្សចាស់ សិស្សានុសិស្សនិងគ្រូបង្រៀន ដែលអ្នកទាំងអស់នេះគឺជាមនុស្សដ៏សំខាន់នៅក្នុងដំណើរការអប់រំនេះ ។ យោងតាមបទសម្ភាសន៍ជាមួយអ្នកភូមិ អ្នកទាំងអស់នោះចង់ឲ្យរឿងរ៉ាវរបស់ខ្លួនត្រូវបានដឹងឮនិងទទួលស្គាល់តាមច្បាប់ទាំងនៅក្នុងនិងក្រៅថ្នាក់រៀន តាមរយៈការស្តាប់និងការសិក្សា ។ ទោះជាការប្រារព្ធធ្វើវេទិកាសាធារណៈនៅខេត្តកំពង់ស្ពឺនៅមានភាពខ្វះខាត ក៏វេទិកានេះគឺជាជំហានដំបូងឆ្ពោះទៅរកការចែករំលែក ការរៀនសូត្រពីរបបខ្មែរក្រហម និងការទទួលយកភាពឈឺចាប់ដែលប្រជាជនកម្ពុជាមួយចំនួនបានជួបប្រទះក្នុងរយៈកាលកន្លងមក ។

## សមាជិកគម្រោង

*ឌី ខាំបូលី*

*វ៉ាន់ថាន់ ពៅដារ៉ា*

*ផេង ពង្សរ៉ាស៊ី*

*ប្រាក់ កែវដារ៉ា*

*លី សុខចំរើន*